# Involuntary patients

About your rights

# អ្នកជំងឺមិនស្ម័គ្រចិត្ត

អំពីសិទ្ធិរបស់លោកអ្នក

Cambodian

## សេចក្តីសង្ខេប

នៅពេលលោកអ្នកឋិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត ឬ ព្យាបាលតាមសហគមន៍ លោកអ្នកៈ

- នឹងមានផែនការព្យាបាលមួយ ហើយអាចចូលរួមនៅក្នុងការធ្វើផែនការព្យាបាលរូបលោកអ្នក
- មានសិទ្ធិទទួលយកនូវមតិយោបល់ទីពីរស្តីពីការព្យាបាលពីពេទ្យឯកទេសជំងឺវិកលចរិត
- មានសិទ្ធិធ្វើការប្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាពិនិត្យឡើងវិញនូវសុខភាពផ្លូវចិត្តប្រឆាំងនឹងការដាក់បទបញ្ជាលើរូបលោកអ្នក
- មានសិទ្ធិសុំយកដំបូន្មានច្បាប់ និងមេធាវីឱ្យធ្វើជាតំណាងលោកអ្នក
- អាចនិយាយជាមួយមិត្តភក្តិ ឬសមាជិកគ្រួសារ និងអាចមានពួកគេធ្វើជាតំណាងលោកអ្នក
- អាចប្តឹងតវ៉ាអំពីការព្យាបាលរបស់លោកអ្នក
- មានសិទ្ធិនៅក្រោម*លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ។*
  *(Charter of Human Rights and Responsibilities).*

លោកអ្នកអាចសួរសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី អ្នកគាំទ្រ ឬភ្ញៀវសាកសួរសុខទុក្ខមកពីសហគមន៍ ដើម្បីជួយលោកអ្នកធ្វើកិច្ចការទាំងនេះ ឬទាក់ទងអង្គការណាមួយដែលមានរាយ ឈ្មោះនៅខាងចុងកូនសៀវភៅនេះ ។

## អ្នកជំងឺមិនស្ម័គ្រចិត្ត

### អំពីសិទ្ធិរបស់លោកអ្នក

កូនសៀវភៅនេះផ្តល់ព័ត៌មានស្តីពីភាពឋិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត ឬបទបញ្ជាព្យាបាលតាមសហគមន៍ និងអំពីសិទ្ធិស្របច្បាប់របស់លោកអ្នក ព្រមទាំងការមានសិទ្ធិទទួលក្រោម*ច្បាប់សុខភាពផ្លូវចិត្តនាឆ្នាំ១៩៨៦* ។ សមាជិកម្នាក់នៃក្រុមព្យាបាលលោកអ្នកនឹងនិយាយជាមួយលោកអ្នកអំពីព័ត៌មានទាំងនេះ ហើយឆ្លើយនូវបណ្តាសំនួររបស់លោកអ្នក ។

ព័ត៌មានត្រូវតែពន្យល់ជាភាសាមួយ ឬតាមមធ្យោបាយមួយដែលលោកអ្នកអាចយល់ ។ កូនសៀវភៅនេះក៏ត្រូវបានបកប្រែជាភាសាមួយចំនួនផងដែរ ។ លោកអ្នកអាចសុំកូនសៀវភៅនេះពីសមាជិកនៃក្រុមព្យាបាល បើសិនវាមានជាភាសាដែលលោកអ្នកចង់បាន ។

លោកអ្នកអាចទទួលបានច្បាប់ចំឡងនៃកូនសៀវភៅនេះជាភាសាដទៃទៀត ដែលមាននៅក្នុងវិបសាយៈ www.health.vic.gov.au/mentalhealth

## មាតិកា


| | |
|---|---|
| បទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត | 2 |
| ការព្យាបាលអ្នកជំងឺក្នុងមន្ទីរពេទ្យ | 3 |
| បទបញ្ជាព្យាបាលតាមសហគមន៍ CTO | 4 |
| បណ្តឹងតវ៉ា និងការពិនិត្យឡើងវិញៈ ក្រុមប្រឹក្សាពិនិត្យឡើងវិញនូវសុខភាពផ្លូវចិត្ត | 5 |
| បណ្តឹង | 8 |
| ការទាក់ទងសំខាន់ៗ | 8 |


### ខ្សែបណ្តាញទូរស័ព្ទផ្តល់ព័ត៌មាន

លោកអ្នកអាចស្តាប់ព័ត៌មានដែលមានថតទុកជាសង្ខេបនូវព័ត៌មានសំខាន់ៗខ្លះ ដែលមាននៅក្នុងកូនសៀវភៅនេះជាភាសាមួយចំនួន ដោយគ្រាន់តែទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទផ្តល់ព័ត៌មាន ។

លេខទូរស័ព្ទមានសរសេរជូននៅផ្នែកខាងក្រោយនៃកូនសៀភៅនេះ ។

ខ្សែទូរស័ព្ទទាំងនេះធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ ។

A Victorian Government initiative

State Government Victoria

ច្បាប់ចំឡងនៃច្បាប់សុខភាពផ្លូវចិត្តមានជូនលោកអ្នកនៅតាមមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ។

បើលោកអ្នកអាចមានចំងល់អំពីព័ត៌មាននេះ និងសិទ្ធិរបស់លោកអ្នក សូមធ្វើការសាកសុំការពន្យល់ពីនរណាម្នាក់ ។ លោកអ្នកអាចសួរសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកក្រុមគ្រួសារ មេធាវី អ្នកគាំទ្រឬភ្ញៀវសាកសួរសុខទុក្ខមកពីសហគមន៍ ។

## *លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ*

*ច្បាប់លក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវរដ្ឋវិចតូរីយ៉ា ឆ្នាំ 2006* ស្វែងរកការលើកកំពស់និងកិច្ចការពារសិទ្ធិមនុស្សជាក់លាក់។ លក្ខន្តិកៈនេះចែងអំពីសិទ្ធិដែលត្រូវការពារ និងតម្រូវឲ្យសេវាសុខភាពផ្លូវចិត្តបំពេញការងារឲ្យសមស្របនឹងសិទ្ធិទាំងនេះ។

លក្ខន្តិកៈនេះក៏បញ្ជាក់ផងដែរនូវពេលនិងរបៀបដែលច្បាប់រឹតត្បិតសិទ្ធិទាំងឡាយ។ ឧទាហរណ៍៖ នៅក្រោមច្បាប់សុខភាពផ្លូវចិត្ត គេអាចឃាត់ខ្លួនលោកអ្នកឲ្យនៅក្នុងសេវាសុខភាពផ្លូវចិត្ត បើវាជាការចាំបាច់ដើម្បីការពារសុខភាពលោកអ្នកឬសុវត្ថិភាពរបស់អ្នកដទៃ។ ប៉ុន្តែការរឹតត្បិតណាមួយលើសេរីភាពលោកអ្នក និងការជ្រៀតជ្រែកណាមួយទៅនឹងសិទ្ធិ ភាពផ្ទាល់ខ្លួន កិត្តិយស និងការគោរពខ្លួនឯងរបស់លោកអ្នក ត្រូវបានធ្វើទៅតាមកំរិតទាបបំផុតដែលជាការចាំបាច់នៅក្នុងកាលៈទេសៈទាំងពួង។

បើលោកអ្នកមានសំណួរណាមួយអំពីលក្ខន្តិកៈនេះ ឬថាតើលក្ខន្តិកៈនេះប្រហែលជាមានផលប៉ះពាល់យ៉ាងណាលើការព្យាបាលលោកអ្នក សូមទាក់ទងអង្គការមួយក្នុងចំណោមអង្គការទាំងឡាយដែលមានរាយឈ្មោះនៅខាងចុងបញ្ចប់នៃកូនសៀវភៅនេះ។

# បទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត

បទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្តគឺជាបទបញ្ជាបិតនៅក្រោមច្បាប់សុខភាពផ្លូវចិត្ត ដែលទាមទារពលរដ្ឋមានជំងឺផ្លូវចិត្តឱ្យទទួលការព្យាបាលជំងឺរបស់ខ្លួន ។ វេជ្ជបណ្ឌិតណែនាំថាលោកអ្នកត្រូវបានដាក់នៅក្នុងបទបញ្ជាព្យាបាល ដោយមិនស្ម័គ្រចិត្ត ដើម្បីឱ្យលោកអ្នកអាចទទួលបានការព្យាបាល ជំងឺផ្លូវចិត្ត ។ តាមមតិយោបល់របស់វេជ្ជបណ្ឌិត រាល់ចំនុចខាងក្រោម ដែលមានចែងនៅក្នុងច្បាប់សុខភាពផ្លូវចិត្តសំរាប់ការព្យាបាលដោយមិនស្ម័គ្រចិត្ត ត្រូវបានយកមកអនុវត្តចំពោះរូបលោកអ្នកដោយសារៈ

- លោកអ្នកបង្ហាញឱ្យឃើញមានជំងឺផ្លូវចិត្ត (តាមនិយមន័យដែលចែងនៅក្នុងច្បាប់ ជំងឺផ្លូវចិត្តគឺជាជំងឺដែលមានលក្ខណៈសំគាល់ដោយសារតែមានការរំខានចំពោះការគិតគូរ អារម្មណ៍ ការយល់ដឹង និងស្មារតីចងចាំ) និង
- ជំងឺផ្លូវចិត្តរបស់លោកអ្នកតំរូវឱ្យមានការព្យាបាល ជាបន្ទាន់ ហើយអាចព្យាបាលបានតាមរយៈការដាក់លោកអ្នកទៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត និង
- ពីព្រោះតែជំងឺផ្លូវចិត្តរបស់លោកអ្នក បទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្តគឺជាការចាំបាច់សំរាប់សុខភាព ឬសុវត្ថិភាពរបស់លោកអ្នក (គឺថាដើម្បីការពារភាពដុនដាបទាំងសុខភាពផ្លូវកាយ ឬផ្លូវចិត្ត ឬដើម្បីព្យាបាល)ឬសំរាប់ការការពារសាធារណជន និង
- លោកអ្នកបានបដិសេធការព្យាបាល ឬមិនអាចផ្តល់ការអនុញ្ញាតិតាមផ្លូវច្បាប់ចំពោះការព្យាបាលដែលចាំបាច់ និង
- ពុំមានមធ្យោបាយងាយស្រួលសំរាប់លោកអ្នក ដើម្បីទទួលការព្យាបាលឱ្យបានគ្រប់គ្រាន់សំរាប់ជំងឺផ្លូវចិត្តរបស់លោកអ្នក ។

## ការពិនិត្យសើរើដំបូងចំពោះ បទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត

នៅក្នុង២៤ម៉ោងនៃការបិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត ពេទ្យឯកទេសជំងឺវិកលចរិតមកពីមន្ទីរពេទ្យសុខភាពផ្លូវចិត្តនឹងសិក្សាពិនិត្យលោកអ្នក ដើម្បីសំរេចថាចំណុចទាំងឡាយដែលរៀបរាប់ខាងលើត្រូវនឹងរូបលោកអ្នកដែរឬទេ ។ ប្រសិនបើចំនុចទាំងនោះត្រូវនឹងរូបលោកអ្នក អ្នកឯកទេសជំងឺវិកលចរិតនឹងបញ្ជាក់ពីបទបញ្ជាហើយលោកអ្នកនឹងទៅជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តក្រោមច្បាប់សុខភាពផ្លូវចិត្ត ។

ពេលនោះពេទ្យវិកលចរិតនឹងបញ្ជូនលោកអ្នកចូលមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ឬក៏ចេញបទបញ្ជាព្យាបាលតាមសហគមន៍ជូនលោកអ្នក ។ បើអាចធ្វើទៅបាន លោកអ្នកនឹងត្រូវគេព្យាបាលជូននៅតាមសហគមន៍ ។ បើសិនលោកអ្នក ត្រូវបានបញ្ជូនព្យាបាលក្នុងនាមជាអ្នកជំងឺស្នាក់ក្នុងមន្ទីរពេទ្យ លោកអ្នក ត្រូវតែស្នាក់នៅក្នុងមន្ទីរពេទ្យ ។ សូមអានព័ត៌មានស្តីពីការព្យាបាលអ្នកជំងឺក្នុងមន្ទីរពេទ្យដែលមាននៅក្នុងកូនសៀវភៅនេះសំរាប់ព័ត៌មានបន្ថែម ។ ប្រសិនបើពេទ្យវិកលចរិតចេញបទបញ្ជាព្យាបាលតាមសហគមន៍ជូនលោកអ្នក សូមលោកអ្នកអានព័ត៌មានស្តីពីការព្យាបាលតាមសហគមន៍ ។ប្រសិនបើលោកអ្នកមានសំណួរអ្វីអំពីការពិនិត្យសើរើករណី របស់លោកអ្នកដែលធ្វើដោយពេទ្យវិកលចរិត ដូចជាពេល ណាពេទ្យវិកលចរិតនឹងមកពិនិត្យលោកអ្នក សូមលោកអ្នកសួរសមាជិកនៃក្រុមព្យាបាល ។

ប្រសិនបើពេទ្យវិកលចរិតពុំជឿថា ចំណុចទាំងអស់នៃបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្តត្រូវនឹងរូបលោកអ្នកទេ នោះបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្តត្រូវគេដកចេញពីរូបលោកអ្នក ។ លោកអ្នកអាចពិភាក្សាពីការព្យាបាលបន្តដោយស្ម័គ្រចិត្តជាមូលដ្ឋានជាមួយប្រធានគ្រប់គ្រងករណី ឬពេទ្យវិកលចរិតរបស់លោកអ្នក ។ បើសិនលោកអ្នកធ្លាប់ជាអ្នកជំងឺក្នុងមន្ទីរពេទ្យ ហើយលោកអ្នក និងពេទ្យវិកលចរិតគិតថា លោកអ្នកនឹងទទួលផលល្អពីការព្យាបាលបន្តទៀតនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត លោកអ្នកអាចសុំបន្តការស្នាក់នៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្តបានតាមមូលដ្ឋានស្ម័គ្រចិត្ត ។

ប្រសិនបើលោកអ្នកមានសំណួរអ្វីអំពីការពិនិត្យសើរើករណីរបស់លោកអ្នកដែលធ្វើដោយពេទ្យវិកលចរិត ដូចជាពេលណាពេទ្យវិកលចរិតនឹងមកពិនិត្យលោកអ្នក សូមលោកអ្នកសួរសមាជិកនៃក្រុមព្យាបាល ។

## ការព្យាបាល

ពេទ្យវិកលចរិតរបស់លោកអ្នកនឹងរៀបចំផែនការនៃការព្យាបាល ដែលតាក់តែងឡើងដើម្បីគាំទ្រនឹងសេចក្ដីត្រូវការរបស់លោកអ្នក ។ លោកអ្នកអាចចូលរួមក្នុងការធ្វើផែនការព្យាបាលនេះ ហើយពេទ្យ វិកលចរិតរបស់លោកនឹងធ្វើការពិចារណានូវចំនង់ចំនូលចិត្ត និងការបារម្ភរបស់លោកអ្នក ។ ពេទ្យវិកលចរិតក៏ពិចារណាផង ដែរពីបំណងរបស់អាណាព្យាបាល សមាជិកគ្រួសារ និងអ្នកថែទាំ លោកអ្នកផ្ទាល់ ដែលជាអ្នកកំពុងតែមើលថែទាំលោកអ្នក (លើកលែងតែលោកអ្នកមិនយល់ព្រម) ព្រមទាំងពិចារណាលើវិធី ព្យាបាលផ្សេងទៀត និងគ្រោះថ្នាក់គួរឱ្យបារម្ភដែលអាចកើតមានដោយ សារតែការព្យាបាលនេះ ។

បើសិនជាពេទ្យវិកលចរិតជឿជាក់ថាការព្យាបាល ពិសេសណាមួយជាការចាំបាច់ ពេលនោះការព្យាបាលនេះ អាចត្រូវបានផ្ដល់ជូនលោកអ្នក បើទោះបីជាលោកអ្នក បដិសេធក្ដី ។ បើករណីនេះកើតមាន ពេទ្យវិកលចរិត របស់លោកអ្នកនឹងពន្យល់ពីមូលហេតុ និងភាពចាំបាច់នៃ ការព្យាបាលនេះ ។ ពេទ្យវិកលចរិត និងសមាជិក ក្រុមព្យាបាលរបស់លោកអ្នកនឹងពិភាក្សាជាមួយលោកអ្នក ពីផែនការនៃការព្យាបាល និងជូនច្បាប់ចំលងនៃផែនការ នេះមួយច្បាប់ដល់លោកអ្នក ។

ពេទ្យវិកលចរិត និងសមាជិកក្រុមព្យាបាលរបស់លោកអ្នក នឹងពិភាក្សាជាទៀងទាត់ជាមួយលោកអ្នកអំពីការវិនិច្ឆ័យរោគ ឱសថព្យាបាល វិធីសាស្ត្រព្យាបាល វិធីព្យាបាលដទៃទៀត និងសេវាកម្មនានាដែលមានជូនលោកអ្នក ។ ពួកគេនឹងពិនិត្យ សើរើ និងកែលំអផែនការព្យាបាលរបស់លោកអ្នកតាម មូលដ្ឋានជាទៀងទាត់ ។

លោកអ្នកអាចមានមិត្តភក្ដិ ឬអ្នកគាំទ្រនៅជាមួយលោកអ្នក នៅខណៈលោកអ្នកកំពុងពិភាក្សាការព្យាបាលជំងឺរបស់លោក អ្នកជាមួយពេទ្យវិកលចរិត ។

សមាជិកគ្រួសារ និងអ្នកថែទាំលោកអ្នកអាចផ្ដល់ការគាំទ្រ និងការថែទាំដ៏ថ្លៃថ្លា នៅខណៈដែលលោកអ្នកកំពុងព្យាបាលជំងឺរបស់ លោកអ្នក ។ ជាទូទៅអ្នកទាំងនេះនឹងអាចទទួលព័ត៌មានអំពីការព្យាបាល របស់លោកអ្នកបាន លុះត្រាតែលោកអ្នកយល់ព្រម ។ ទោះជាដូច្នេះក្ដី ប្រសិនបើអាណាព្យាបាល ឬសមាជិកគ្រួសារ ឬអ្នកថែទាំលោកអ្នក ដោយផ្ទាល់ត្រូវការព័ត៌មានដើម្បីថែទាំលោកអ្នក ពេលនោះសមាជិកនៃ ក្រុមព្យាបាលលោកអ្នកអាចផ្ដល់ព័ត៌មានដល់ពួកគេបាន បើ ទោះបីជាលោកអ្នកមិនយល់ព្រមក្ដី ។

## មតិយោបល់ទីពីរ

វាជាសិទ្ធិរបស់លោកអ្នកដើម្បីទទួលយកយោបល់ទីពីរស្ដីពី ជំងឺផ្លូវចិត្ត និងការព្យាបាលរបស់លោកអ្នក ។ ប្រធានគ្រប់គ្រងករណី ឬពេទ្យវិកល ចរិតរបស់លោកអ្នកអាចរៀបចំកិច្ចការនេះនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ក៏បាន ឬក៏ពួកគេអាចជួយលោកអ្នកក្នុងការជ្រើសរើស ពេទ្យវិកលចរិត ផ្ទាល់ខ្លួនរបស់លោកអ្នកក៏បាន ។ ប្រសិនបើលោកអ្នកជ្រើសរើសពេទ្យ វិកលចរិតឯកជន លោកអ្នកប្រហែលជាត្រូវបង់ថ្លៃឈ្នួល ។ លោកអ្នក អាចពិភាក្សាពីមតិយោបល់ទីពីរនេះជាមួយពេទ្យវិកលចរិត របស់លោកអ្នក ដែលជាអ្នកទទួលខុសត្រូវចំពោះការធ្វើសេចក្ដីសំរេចចិត្តចុងក្រោយអំពីការ ព្យាបាលដែលលោកអ្នកនឹងទទួល ។

## សិទ្ធិទទួលព័ត៌មាន

វាជាសិទ្ធិរបស់លោកអ្នកក្រោមច្បាប់សេរីភាពនៃព័ត៌មាន ដើម្បីដាក់ពាក្យសុំសិទ្ធិទទួលព័ត៌មានចេញពីឯកសារស្ដីពី ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដែលមាននៅក្នុងមន្ទីរពេទ្យ សុខភាពផ្លូវចិត្ត ។ បើសិនជាលោកអ្នកចង់បានសិទ្ធិទទួលព័ត៌មាននេះ លោកអ្នកអាចសុំជំនួយពីសមាជិកក្រុមព្យាបាល ឬពីមន្ត្រីទទួល បន្ទុកផ្នែកសេរីភាពព័ត៌មានរបស់មន្ទីរពេទ្យសុខភាពផ្លូវចិត្ត ដើម្បីដាក់ពាក្យសុំព័ត៌មាននេះ ។

អង្គការដែលអាចជួយលោកអ្នកក្នុងការដាក់ពាក្យសុំសិទ្ធិទទួលព័ត៌មាន មានរាយឈ្មោះនៅខាងក្រោយនៃកូនសៀវភៅនេះ ។

# ការព្យាបាលអ្នកជំងឺស្នាក់ក្នុងមន្ទីរពេទ្យ

ផ្នែកនេះនៃកូនសៀវភៅមានព័ត៌មានស្ដីពីសិទ្ធិ និងការមានសិទ្ធិទទួល របស់លោកអ្នក បើសិនលោកអ្នកត្រូវបានបញ្ជូនទៅ កាន់មន្ទីរពេទ្យផ្លូវចិត្តតាមបទបញ្ជាព្យាលដោយមិនស្ម័គ្រចិត្ត ។

## ការសុំច្បាប់សំរាកពីការព្យាបាល

លោកអ្នកប្រហែលជាត្រូវអនុញ្ញាតឱ្យសំរាកពីការព្យាបាលសំរាប់រយៈ ពេលខ្លីមួយ (ឧទាហរណ៍ការសំរាករយៈពេល២-៣ម៉ោង ការសំរាកមួយយប់ ឬមួយចុងសប្ដាហ៍) ដើម្បីទៅលេងក្រុមគ្រួសារ ឬមិត្តភក្ដិ ឬសំរាប់គោលបំណងផ្សេងៗទៀត ។ បើសិនជាលោកអ្នក សំរាកពីការព្យាបាល លោកអ្នក គួរតែនិយាយជាមួយសមាជិកក្រុមព្យាបាល ។ ពេទ្យវិកលចរិតរបស់លោកអ្នកនឹងធ្វើសេចក្ដីសំរេចចិត្តចុងក្រោយអំពី សំណើសុំច្បាប់សំរាកពីការព្យាបាលនៅក្នុងមន្ទីរពេទ្យរបស់លោកអ្នក ។

## ការដាក់អ្នកជំងឺក្នុងទីដាច់ដោយឡែកតែឯង និងការចាប់បង្ខាំងទុក

### ការដាក់អ្នកជំងឺក្នុងទីដាច់ដោយឡែកតែឯង

ការដាក់អ្នកជំងឺក្នុងទីដាច់ដោយឡែកតែឯង គឺនៅពេលណាដែលជនម្នាក់ ត្រូវបានគេរក្សាទុកនៅក្នុងបន្ទប់មួយតែម្នាក់ឯង ដែលក្នុងនោះ រាល់ទ្វារបង្អួចត្រូវគេចាក់សោជាប់ពីខាងក្រៅ ។ ករណីនេះ កើតមានឡើងនៅពេលណាចាំបាច់ ដើម្បីការពារអ្នកជំងឺ ឬអ្នក ដទៃពីគ្រោះថ្នាក់ជាបន្ទាន់ ឬគ្រោះថ្នាក់ដែលអាចកើតមានដល់សុខភាព ឬសុវត្ថិភាពរបស់គេ ឬដើម្បីការពារគេពីការគេចខ្លួន ។ វិធីនេះត្រូវបាន ប្រើនៅពេលដែលវិធីផ្សេងៗទៀតដើម្បីរក្សាសុវត្ថិភាពទទួលបរាជ័យ ។

### ការឃាំងខ្លួនដោយប្រើឧបករណ៍

ការឃាំងខ្លួននេះគឺជាការប្រើប្រាស់ឧបករណ៍មួយ ដូចជាខ្សែឬ ច្រវ៉ាក់ចងជាដើមដើម្បីកុំឱ្យអ្នកជំងឺអាចមានសេរីភាពធ្វើសកម្មភាព ។ ការចាប់ចងទុកនេះត្រូវបានប្រើប្រាស់ ដើម្បីអាចឱ្យអ្នកជំងឺទទួល បានការព្យាបាលដើម្បីការពារអ្នកជំងឺពីការធ្វើឱ្យរងរបួសខ្លួនឯង ឬធ្វើឱ្យរបួសដល់អ្នកដទៃ ឬដើម្បីការពារកុំឱ្យអ្នកជំងឺធ្វើការ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។

## ការយល់ព្រម និងការត្រួតពិនិត្យលើការដាក់អ្នកជំងឺក្នុងទីដាច់ដោយឡែកតែឯង និងការចាប់បង្ខាំងទុក

ការដាក់អ្នកជំងឺនៅក្នុងកន្លែងដាច់ដោយឡែក និងការចាប់បង្ខាំងទុកទុកអាចអនុញ្ញាតឱ្យធ្វើឡើងបានលុះត្រាតែមានការយល់ព្រមពីអ្នកឯកទេសព្យាបាលជំងឺវិកលចរិត ក្នុងករណីសង្គ្រោះបន្ទាន់ ឬមានការផ្តល់អំណាចពីគិលានុបដ្ឋាកជាន់ខ្ពស់ទទួលបន្ទុកការងារនេះ ។ វិធីនេះអាចយកមកប្រើប្រាស់បាន លុះត្រាតែមានហេតុផលដូចបានរៀបរាប់ខាងលើ ។

បើសិនលោកអ្នកត្រូវបានដាក់ចូលទៅក្នុងទីដាច់ដោយឡែក ឬចាប់ចងទុក ពេលនោះបុគ្គលិកព្យាបាលត្រូវតែផ្តល់ជូនលោកអ្នកនូវកន្លែងសំរាន្តសមរម្យ សំលៀកបំពាក់ ចំណី អាហារ និងទឹកឱ្យបានសមស្របតាមពេលវេលា ។ លោកអ្នកអាចសុំចំណីអាហារ និងទឹកពីបុគ្គលិកនៅពេលណាដែលលោកអ្នកចង់ទទួលទាន ។ បុគ្គលិកត្រូវតែផ្តល់ការរៀបចំជូនឱ្យបានគ្រប់គ្រាន់នូវបន្ទប់អនាម័យបង្គន់រួមទាំងឱកាសលាងសំអាតទៀតផង ។

យ៉ាងហោចណាស់ គិលានុបដ្ឋាកត្រូវតែពិនិត្យឡើងវិញនូវល័ក្ខខ័ណ្ឌសុខភាពរាងកាយ និងផ្លូវចិត្តជារៀងរាល់១៥នាទីម្តង ។ វេជ្ជបណ្ឌិតក៏ត្រូវឆែកពិនិត្យលោកអ្នក យ៉ាងហោចណាស់ ៤ម៉ោងម្តង លើកលែងតែពេទ្យវិកលចរិតគិតថាពុំចាំបាច់ពិនិត្យញឹកញាប់ពេកទេ ។ បើសិនលោកអ្នកត្រូវគេចាប់បង្ខាំងទុក ពេលនោះលោកអ្នកត្រូវបានគេពិនិត្យឃ្លាំមើលជាប់រហូត ។

### សំបុត្រ និងការនិយាយទូរស័ព្ទ

លោកអ្នកអាចទាក់ទងមនុស្សតាមរយៈសំបុត្រ ឬទូរស័ព្ទបាន ។ សំបុត្ររបស់លោកអ្នកនឹងមិនត្រូវបានគេបើកមើលឡើយ ។

### ការបញ្ជូនទៅសេវាកម្មផ្សេងៗ

លោកអ្នកអាចត្រូវបានគេបញ្ជូនទៅកាន់សេវាកម្មថែរក្សាជំងឺផ្លូវចិត្តផ្សេងទៀត ប្រសិនបើអ្នកឯកទេសជំងឺវិកលចរិតជឿជាក់ថា លោកអ្នកនឹងទទួលបានសារប្រយោជន៍ពីការបញ្ជូនទៅកាន់សេវាកម្មផ្សេងនេះ ឬក៏ការបញ្ជូននេះជាការចាំបាច់សំរាប់ការព្យាបាលរូបលោកអ្នក ។ បើសិនជាលោកអ្នកមិនចង់ឱ្យគេបញ្ជូនទេ លោកអ្នកគួរតែនិយាយជាមួយអ្នកឯកទេសព្យាបាលជំងឺវិកលចរិតរបស់លោកអ្នក ឬក៏លោកអ្នកអាចប្តឹងតវ៉ា ទៅកាន់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត ។ ប្រសិនបើ គេបញ្ជូនលោកអ្នកទៅសេវាកម្មផ្សេងនៅមុនការប្តឹងតវ៉ា ពេលនោះក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្តនឹងធ្វើសេចក្តីសំរេចចិត្តពីការវិលត្រលប់មកកាន់សេវាកម្មចាស់នៅក្នុងតុលាការបណ្តឹងតវ៉ា ។

### បទបញ្ជាព្យាបាលនៅតាមសហគមន៍

ប្រសិនបើពេទ្យវិកលចរិតរបស់លោកអ្នកជឿជាក់ថា លោកអ្នកអាចរស់នៅក្នុងសហគមន៍បាន នៅខណៈដែលលោកអ្នកទទួលការព្យាបាលដែលលោកអ្នកត្រូវការ ពេលនោះលោកអ្នកអាចត្រូវគេដាក់ចូលទៅក្នុងបទបញ្ជាព្យាបាលនៅតាមសហគមន៍ ។ ដើម្បីស្វែងយល់បន្ថែមអំពីបទបញ្ជានេះ សូមលោកអ្នកអានផ្នែកបទបញ្ជាព្យាបាលនៅតាមសហគមន៍ដែលមាននៅក្នុងកូនសៀវភៅនេះ ព្រមទាំងសួរសមាជិកក្រុមព្យាបាល ដើម្បីឱ្យគេពន្យល់បទបញ្ជានេះដល់លោកអ្នក ។

### ការចេញពីស្ថានភាពនៃអ្នកជំងឺដោយមិនស្ម័គ្រចិត្ត

បើសិនជាពេទ្យវិកលចរិតរបស់លោកអ្នកជឿជាក់ថា លោកអ្នកពុំមានចំនុចណាមួយនៅក្នុងបណ្តាចំនុចនៃលក្ខណៈសំគាល់ជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ពេលនោះលោកអ្នកពុំនៅក្នុងបទបញ្ជាព្យាបាលដោយស្ម័គ្រចិត្តទៀតទេ ហើយលោកអ្នក នឹងមានសេរីភាពដើម្បីចាកចេញពីមន្ទីរពេទ្យ ។ ទោះជាដូចនេះក្តី បើលោកអ្នក និងពេទ្យវិកលចរិតរបស់លោកអ្នកគិតថា លោកអ្នកនឹងទទួលលទ្ធផលល្អពីការព្យាបាលបន្តនៅក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត នោះលោកអ្នកអាចសុំស្នាក់នៅក្នុងមន្ទីរពេទ្យបន្ត តាមមូលដ្ឋានស្ម័គ្រចិត្ត ។

បើពេលណាលោកអ្នកមិនចង់នៅជាអ្នកជំងឺដោយស្ម័គ្រចិត្ត លោកអ្នកអាចនិយាយទៅកាន់ពេទ្យវិកលចរិត ឬសមាជិកក្រុមព្យាបាលរបស់លោកអ្នក ឬលោកអ្នកអាចដាក់ពាក្យប្តឹងតវ៉ា ទៅកាន់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត ។ ទោះបីជាលោកអ្នកប្តឹងតវ៉ាក្តី មិនប្តឹងក្តី ក៏ក្រុមប្រឹក្សានេះនឹងនៅតែចាប់ផ្តើមធ្វើការពិនិត្យសើរើបទបញ្ជាក្នុងអំឡុងពេល៨សប្តាហ៍ នៃពេលដែលលោកអ្នកក្លាយជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ហើយបន្ទាប់មកការសើរើនេះកើតមានរៀងរាល់ពេល១២ខែម្តងយ៉ាងតិចបំផុត ប្រសិនបើលោកអ្នកនៅតែបន្តជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ។ ពេទ្យវិកលចរិតរបស់លោកអ្នកនឹងពិនិត្យសើរើករណីលោកអ្នកជា ទៀងទាត់ ដើម្បីឱ្យដឹងថាតើលោកអ្នកគួរតែលែងជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តទៀតឬអត់ ។

## បទបញ្ជាព្យាបាលតាមសហគមន៍ CTO

ផ្នែកនេះនៃកូនសៀវភៅមានព័ត៌មានស្តីពីសិទ្ធិ និងការមានសិទ្ធិទទួលរបស់លោកអ្នក បើសិនលោកអ្នកជាអ្នកជំងឺព្យាបាលតាមសហគមន៍ ។

បទបញ្ជាព្យាបាលតាមសហគមន៍ គឺជាបញ្ជាក្រោមច្បាប់សុខភាពផ្លូវចិត្ត ដែលអាចឱ្យអ្នកជំងឺដោយមិនស្ម័គ្រចិត្តទៅរស់នៅក្នុងសហគមន៍ នៅខណៈដែលគេទទួលការព្យាបាលជំងឺផ្លូវចិត្តរបស់គេ ។

បើសិនជាពេទ្យវិកលចរិតរបស់លោកអ្នកជឿជាក់ថា លោកអ្នកអាចទទួលការព្យាបាលដែលលោកអ្នកត្រូវការ នៅខណៈដែលលោកអ្នករស់នៅក្នុងសហគមន៍ ពេលនោះលោកអ្នកនឹងឋិតនៅក្នុងបទបញ្ជាព្យាបាលតាមសហគមន៍ ។ លោកអ្នកនៅតែជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តម្នាក់ ដែលឋិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត បើទោះជាលោកអ្នកកំពុងតែរស់នៅក្នុងសហគមន៍ក្នុងបទបញ្ជាព្យាបាលតាមសហគមន៍ក្តី ។

### ការធ្វើផែនការសំរាប់បទបញ្ជាព្យាបាលតាមសហគមន៍

ពេទ្យវិកលចរិតរបស់លោកអ្នកនឹងនិយាយជាមួយលោកអ្នកអំពីបទបញ្ជាព្យាបាលតាមសហគមន៍ និងរៀបចំផែនការព្យាបាលថ្មីមួយ ។ លោកអ្នកអាចចូលរួមក្នុងការធ្វើផែនការនៃបទបញ្ជា របស់លោកអ្នក និងផែនការព្យាបាលរបស់លោកអ្នក ។ ផែនការព្យាបាលរបស់លោកអ្នកនឹងមានរាប់បញ្ចូលការវាយតំលៃមួយអំពីសេចក្តីត្រូវការរបស់លោកអ្នកសំរាប់ការព្យាបាលជាបន្ត និងការគាំទ្រនៅក្នុងសហគមន៍ ព្រមទាំងអំពីវិធីដ៏ល្អបំផុតសំរាប់បំពេញកិច្ចការទាំងនេះជូនលោកអ្នក ។ ចំណង់ចំណូលចិត្តរបស់លោកអ្នកក៏ត្រូវបានគេពិចារណាដែរ ឧទាហរណ៍លោកអ្នកអាចមានវេជ្ជបណ្ឌិតពិសេស ដែលលោកអ្នកចង់បាន ដើម្បីត្រួតពិនិត្យបទបញ្ជាព្យាបាល ។

ពេទ្យវិកលចរិត ឬសមាជិកក្រុមព្យាបាលរបស់លោកអ្នក នឹងពិភាក្សាផែនការព្យាបាលលោកអ្នកជាមួយលោកអ្នក និងផ្តល់ច្បាប់ចំឡងផែនការនេះមួយច្បាប់ជូនលោកអ្នក ។ ផែនការនេះមានបណ្តុំចំណុចដូចខាងក្រោម៖

- គំរោងបញ្ជាក់ពីការព្យាបាលរបស់លោកអ្នក
- ឈ្មោះពេទ្យវិកលចរិតដែលត្រួតពិនិត្យការ ព្យាបាលរបស់លោកអ្នក
- ឈ្មោះវេជ្ជបណ្ឌិតដែលនឹងត្រួតពិនិត្យការព្យាបាល របស់លោកអ្នក
- ឈ្មោះប្រធានគ្រប់គ្រងករណីរបស់លោកអ្នក
- ទីកន្លែង និងពេលវេលា ដែលលោកអ្នកទទួលការ ព្យាបាល
- ចំនួនរបាយការណ៍ ស្តីពីការព្យាបាលរបស់លោកអ្នក ដែលវេជ្ជបណ្ឌិតត្រួតពិនិត្យត្រូវតែសរសេរជូនពេទ្យវិកលចរិត ដែលធ្វើការឃ្លាំមើល
- កិច្ចការផ្សេងៗដែលពេទ្យវិកលចរិតគិតថាសមស្រប

## ល័ក្ខខ័ណ្ឌនៃបទបញ្ជាព្យាបាលតាមសហគមន៍ (CTO)

លោកអ្នកនឹងទទួលបានច្បាប់ចំឡងស្តីពី CTO មួយច្បាប់ ។ CTO នឹងប្រាប់អំពីរយៈពេលនៃបទបញ្ជា ដែលអាចមានរហូតដល់១២ខែ ។ ជួនកាល CTO បញ្ជាក់ពីទីកន្លែងដែលលោកអ្នកត្រូវតែរស់នៅ ប្រសិនបើវាជាការចាំបាច់សំរាប់ការព្យាបាលជំងឺរបស់លោកអ្នក ។ ពេទ្យវិកលចរិតរបស់លោកអ្នកអាចកែប្រែល័ក្ខខ័ណ្ឌទាំងនេះពីពេលមួយទៅពេលមួយទៀត ហើយនឹងពិភាក្សាពីហេតុផលទាំងឡាយជាមួយលោកអ្នក ។

ប្រសិនបើលោកអ្នកមិនសប្បាយចិត្តជាមួយនឹងលក្ខខណ្ឌណាមួយ លោកអ្នកគួរតែនិយាយជាមួយសមាជិកក្រុមព្យាបាលលោកអ្នក ឬលោកអ្នកអាចដាក់បណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត ។

ពេទ្យវិកលចរិតរបស់លោកអ្នកអាចបន្តពេល CTO បើសិនជាលោកអ្នកនៅតែមានរាល់ចំនុចដែលជាលក្ខណៈសំគាល់ អ្នកជំងឺដោយមិនស្ម័គ្រចិត្ត ហើយការព្យាបាលដែលលោកអ្នកត្រូវការនៅតែអាចមានបន្តតាមបទបញ្ជាព្យាបាល ។ បើសិនជាCTO ត្រូវបានបន្តក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្តនឹងពិនិត្យសើរើការបន្តពេលនេះ ។

ប្រសិនបើពេទ្យវិកលចរិតរបស់លោកអ្នកមិនបន្តពេល CTO ទេ បទបញ្ជានេះនឹងផុតកំណត់ ហើយលោកអ្នកនឹងមិនមែនជាអ្នកជំងឺដោយស្ម័គ្រចិត្តទៀតទេ ។

## និរាករណ៍នៃបទបញ្ជាព្យាបាលតាមសហគមន៍

ប្រសិនបើលោកអ្នកមិនគោរពតាមបទបញ្ជា ឬផែនការព្យាបាលទេ សមាជិកក្រុមព្យាបាលនឹងព្យាយាមជួយលោកអ្នកឱ្យគោរពតាមបទបញ្ជានេះ ។ ប៉ុន្តែបើលោកអ្នកនៅតែពុំគោរពតាមទៀត ហើយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដែលអាចកើតមាន ដែលបណ្តាលឱ្យសុខភាពលោកអ្នកកាន់តែដុនដាប ពីព្រោះតែការមិនគោរពបទបញ្ជារបស់លោកអ្នក ពេលនោះពេទ្យវិកលចរិតរបស់លោកអ្នក អាចនិរាករណ៍ CTO ហើយលោកអ្នកត្រូវតែត្រឡប់ទៅកាន់ មន្ទីរពេទ្យសុខភាពផ្លូវចិត្តសំរាប់ការព្យាបាលវិញ ។

CTOរបស់លោកអ្នកអាចត្រូវគេនិរាករណ៍ ប្រសិនបើពេទ្យវិកលចរិតជឿជាក់ថា ជំងឺរបស់លោកអ្នកនឹងអាចមានសភាពគ្រាន់បើបានលុះត្រាតែលោកអ្នកនៅព្យាបាលក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ។

បើសិនជា CTO របស់លោកអ្នកត្រូវបាននិរាករណ៍ នោះគេនឹងប្រឹងប្រែងយ៉ាងសមរម្យ ដើម្បីប្រាប់លោកអ្នក បន្ទាប់មកលោកអ្នកត្រូវតែវិលត្រឡប់ទៅកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្តវិញ ។

## ការចាកចេញពីបទបញ្ជាព្យាបាលតាមសហគមន៍

ប្រសិនបើពេទ្យវិកលចរិតជឿជាក់ថា លោកអ្នក លែងមានចំនុចណាមួយនៃលក្ខណៈអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ពេលនោះគេឱ្យលោកអ្នកចាកចេញពី CTO ហើយលោកអ្នក ក៏លែងជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តទៀតដែរ ។ លោកអ្នក អាចពិភាក្សាការព្យាបាលបន្តតាមមូលដ្ឋានស្ម័គ្រចិត្តជាមួយប្រធានគ្រប់គ្រងករណី ឬជាមួយពេទ្យវិកលចរិតរបស់ លោកអ្នក ។

បើនៅខណៈណាមួយលោកអ្នកចង់ចាកចេញពី CTO លោកអ្នកគួរតែនិយាយជាមួយពេទ្យវិកលចរិត ឬសមាជិកក្រុមព្យាបាលរបស់លោកអ្នក ឬលោកអ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាព ។ បើទោះជាលោកអ្នកដាក់ ឬមិនដាក់ពាក្យបណ្តឹងតវ៉ាក្តី ក៏ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពនឹងផ្តួចផ្តើមធ្វើការសើរើពិនិត្យបទបញ្ជាក្នុងអំឡុងពេល៨សប្តាហ៍នៃពេលដែលលោកអ្នកក្លាយជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ហើយបន្ទាប់មកការពិនិត្យឡើងវិញនេះកើតមានក្នុងរយៈពេលយ៉ាងតិច១២ខែម្តងប្រសិនបើលោកអ្នក នៅតែជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តជាបន្តទៀត ។ ពេទ្យជំងឺវិកលចរិត របស់លោកអ្នកនឹងពិនិត្យសើរើករណីលោកអ្នកជាទៀងទាត់ ដើម្បីឱ្យ ដឹងថាតើលោកអ្នកគួរតែលែងជាអ្នកជំងឺដោយមិនស្ម័គ្រចិត្តទៀតឬអត់ ។

# បណ្តឹងតវ៉ា និងការសើរើពិនិត្យសុខភាពផ្លូវចិត្ត៖ ក្រុមប្រឹក្សាសើរើ ពិនិត្យសុខភាពផ្លូវចិត្ត

ផ្នែកនេះនៃកូនសៀវភៅមានព័ត៌មានស្តីពី សិទ្ធិ និងការមានសិទ្ធិទទួលរបស់លោកអ្នក ដើម្បីដាក់ពាក្យបណ្តឹងតវ៉ា និងដើម្បីសើរើពិនិត្យសុខភាពផ្លូវចិត្ត ដែលធ្វើឡើងដោយក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត ។

## តួនាទីរបស់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត

ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពគឺជាតុលាការឯករាជ្យ ដែល៖

- បើកការកាត់ក្តីរបស់អ្នកជំងឺដោយមិនស្ម័គ្រចិត្តដែលឋិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត ឬបទបញ្ជាព្យាបាលតាមសហគមន៍ ហើយដែលចង់ចាកចេញពីបទបញ្ជាទាំងនេះ ។
- ធ្វើការសើរើពិនិត្យអ្នកជំងឺដោយមិនស្ម័គ្រចិត្តទាំងអស់នៅ៨សប្តាហ៍ក្នុងពេលដែលគេមានបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត ដើម្បីសំរេចថាតើអាចឱ្យអ្នកជំងឺចាកចេញពីបទបញ្ជាបានឬទេ ។
- ពិនិត្យសើរើអ្នកជំងឺដោយមិនស្ម័គ្រចិត្តទាំងអស់យ៉ាងហោចណាស់រៀងរាល់១២ខែម្តង ដើម្បីសំរេចថាតើអាចឱ្យអ្នកជំងឺចាកចេញពីបទបញ្ជាបានឬទេ ។

- កាត់ក្ដីបណ្ដឹងតវ៉ារបស់អ្នកជំងឺដែលមិនចង់ឱ្យគេបញ្ជូនទៅមន្ទីរពេទ្យសុខភាពផ្លូវចិត្តផ្សេងទៀត ។
- ពិនិត្យសើរើការពន្យាពេលនៃបទបញ្ជាព្យាបាលតាមសហគមន៍ទាំងអស់ ។

នៅក្នុងរាល់ការពិនិត្យសើរើ ឬការប្ដឹងតវ៉ា ក្រុមប្រឹក្សានេះក៏ពិនិត្យសើរើផែនការព្យាបាលរបស់លោកអ្នកផងដែរ ។

## សិទ្ធិរបស់លោកអ្នកក្នុងការប្ដឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត

វាជាសិទ្ធិរបស់លោកអ្នក ដើម្បីដាក់ពាក្យបណ្ដឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្តនៅពេលណាក៏បាន ។ បើសិនជាលោកអ្នកចង់ប្ដឹងតវ៉ា សូមសួររកពាក្យបណ្ដឹងពីសមាជិកក្រុមព្យាបាល រួចបំពេញពាក្យបណ្ដឹងនេះ ហើយសុំឱ្យសមាជិកក្រុមព្យាបាលផ្ញើពាក្យនេះទៅកាន់ក្រុមប្រឹក្សា ។ បើសិនជាគ្មានពាក្យបណ្ដឹងទេ លោកអ្នកអាចសរសេរសំបុត្រ ឬអ៊ីម៉ែលការប្ដឹងតវ៉ានេះទៅកាន់ក្រុមប្រឹក្សាដោយបញ្ជាក់ឈ្មោះលោកអ្នក ឈ្មោះមន្ទីរពេទ្យសុខភាពផ្លូវចិត្តលោកអ្នកស្នាក់នៅ និងអំពីអ្វីដែលលោកអ្នកចង់ប្ដឹងតវ៉ា ។ ក្រុមប្រឹក្សានឹងធ្វើការកាត់ក្ដីនៃបណ្ដឹងតវ៉ានេះជាបន្ទាន់ ។ បើសិនលោកអ្នកត្រូវការជំនួយដើម្បីបំពេញពាក្យប្ដឹង ឬដើម្បីអ្វីផ្សេងទៀត លោកអ្នកគួរតែស្នើសុំសមាជិកព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬភ្ញៀវសាកសួរសុខទុក្ខមកពីសហគមន៍ ដើម្បីឱ្យគេជួយលោកអ្នក ។

## ព័ត៌មានលំអិតសំរាប់ការទាក់ទងរបស់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត

ដើម្បីផ្ញើទូរសារ សំបុត្រ ឬអ៊ីម៉ែលនៃពាក្យបណ្ដឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត ឬដើម្បីស្វែងយល់ពីព័ត៌មានផ្សេងៗទៀត សូមប្រើប្រាស់ព័ត៌មានលំអិតសំរាប់ការទាក់ទងដូចខាងក្រោម៖

Executive Officer
Mental Health Review Board
Level 30, Marland House
570 Bourke Street, Melbourne Victoria 3000

ទូរស័ព្ទលេខ៖ 8601 5270
ទូរស័ព្ទអត់គិតថ្លៃលេខ៖ 1800 242 703
ទូរសារលេខ៖ 8601 5299

អ៊ីម៉ែល៖ mhrb@mhrb.vic.gov.au
វ៉ិបសាយ៖ www.mhrb.vic.gov.au

## សុខភាពផ្លូវចិត្ត

ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្តនឹងផ្ញើជូនលោកអ្នកនូវកំនត់ត្រាដោយប្រាប់ពីថ្ងៃខែ ពេលវេលា និងទីកន្លែងដែលបណ្ដឹងរបស់លោកអ្នកត្រូវការកាត់ក្ដី ។ ពេទ្យព្យាបាលវិកលចរិត និងប្រធានគ្រប់គ្រងករណីរបស់លោកអ្នកក៏ទទួលបានកំនត់ត្រានៃការកាត់ក្ដីនេះដែរ ។ វាជាសិទ្ធិរបស់លោកអ្នកដើម្បីចូលរួមការកាត់ក្ដីនេះ លើកលែងតែក្រុមប្រឹក្សានេះសំរេចចិត្តថា ការកាត់ក្ដីនេះជាការមិនល្អសំរាប់សុខភាពរបស់លោកអ្នក ។ លោកអ្នកត្រូវគេលើកទឹកចិត្តឱ្យចូលរួម និងលើកបង្ហាញករណីរបស់លោកអ្នកនៅក្នុងកាត់ក្ដីនេះ ហើយលោកអ្នកអាចមានអ្នកណាម្នាក់ចូលរួមជាមួយដើម្បីជួយគាំទ្រ ឬនិយាយជួសលោកអ្នក ដូចជាអ្នកគាំទ្រ មេធាវី វេជ្ជបណ្ឌិតឯកជន មិត្តភក្តិ ឬសមាជិកគ្រួសារ ។ ប្រសិនបើលោកអ្នកមិនអាចចូលរួមការកាត់ក្ដីនេះបាន លោកអ្នកគួរតែជំរាបក្រុមប្រឹក្សានេះឱ្យបានឆាប់រហ័ស ។

មុនចូលរួមការកាត់ក្ដី សូមលោកអ្នកអានឯកសារ ដែលគេជូនទៅក្រុមប្រឹក្សាសំរាប់ការកាត់ក្ដីរបស់លោកអ្នក (សូមមើលព័ត៌មានខាងក្រោម) ហើយសូមគិតអំពីអ្វីដែលលោកអ្នកបំរុងនឹងនិយាយទៅកាន់ក្រុមប្រឹក្សា ។ លោកអ្នកប្រហែលជា ចង់ជូនក្រុមប្រឹក្សានេះនូវព័ត៌មានជាលាយលក្ខអក្សរ ។ គ្រួសារ មិត្តភក្តិ របស់លោកអ្នក ឬអ្នកណាម្នាក់ដែលលោកអ្នកគោរពអាចសរសេរសំបុត្រ ឬអាចចូលរួមការកាត់ក្ដីនេះដើម្បីជួយគាំទ្របណ្ដឹងតវ៉ា ឬការសើរើពិនិត្យសុខភាពផ្លូវចិត្តរបស់លោកអ្នក ។

បើសិនជាលោកអ្នកមានសេចក្ដីត្រូវការពិសេស ដូចជាត្រូវការអ្នកបកប្រែភាសាលោកអ្នកគួរតែពិភាក្សាកិច្ចការនេះជាមួយសមាជិកក្រុមព្យាបាល ឬទាក់ទងទៅក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត ។ ក្រុមប្រឹក្សានេះនឹងរៀបចំអ្នកបកប្រែជូន បើជាការចាំបាច់ ។

អង្គការទាំងឡាយដែលអាចជួយលោកអ្នកក្នុងកិច្ចការបណ្ដឹង តវ៉ា ឬពិនិត្យសើរើ មានរាយឈ្មោះនៅខាងក្រោយនៃកូនសៀវភៅនេះ ។

## សិទ្ធិទទួលបានឯកសារនានាសំរាប់ការកាត់ក្ដី

លោកអ្នក និងតំណាងលោកអ្នកនឹងមានឱកាសអានឯកសារទាំងឡាយដែលនឹងផ្ដល់ជូនក្រុមប្រឹក្សាសំរាប់ការកាត់ក្ដីរបស់លោកអ្នក យ៉ាងហោចណាស់ក៏២៤ម៉ោងមុនការកាត់ក្ដីប្រព្រឹត្តឡើង ក្នុងនោះរួមមានឯកសារវេជ្ជសាស្ត្រ និងរបាយការណ៍ របស់ពេទ្យវិកលចរិតជូនក្រុមប្រឹក្សា ។ បើទោះជាដូចនេះក្ដីក៏ពេទ្យវិកលចរិតលោកអ្នកអាចដាក់ពាក្យសុំក្រុមប្រឹក្សាមិនឱ្យលោកអ្នកឃើញឯកសារណាមួយ ឬ ផ្នែកណាមួយនៃឯកសារ បើសិនសិនជាគេជឿជាក់ថា៖

- ការឃើញឯកសារនឹងបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពលោកអ្នក ឬសុខភាព និងសុវត្ថិភាពរបស់ជនណាម្នាក់ទៀត ឬ
- ព័ត៌មាននៅក្នុងឯកសារត្រូវបានផ្ដល់ដោយលាក់ការណ៍ ឬជាព័ត៌មានផ្ទាល់ខ្លួនអំពីជនម្នាក់ទៀត ។

បើសិនជាមានពាក្យសុំដាក់រារាំងលោកអ្នកមិនឱ្យមើលឯកសារណាមួយ ឬផ្នែកណាមួយនៃឯកសារ សមាជិកម្នាក់នៃក្រុមនព្យាបាលនឹងនិយាយប្រាប់ ព្រមទាំងពន្យល់ដល់លោកអ្នកពីកិច្ចការនេះ ។ ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពនឹងធ្វើសេចក្ដីសំរេចចិត្តចុងក្រោយអំពីថាតើលោកអ្នកអាចមើលឯកសារទាំងមូល ឬក៏ផ្នែកណាមួយនៃឯកសារ ឬក៏លោកអ្នកមិនអាចមើលឯកសារអ្វីទាំងអស់ ។

ប្រសិនបើក្រុមប្រឹក្សាសំរេចចិត្តថា លោកអ្នកមិនគួរមើលឯកសារណាមួយ ឬផ្នែកណាមួយនៃឯកសារទេ ពេលនោះក្រុមប្រឹក្សាប្រហែលជាអនុញ្ញាតឱ្យអ្នកតំណាងរបស់លោកអ្នកមើលឯកសារជំនួសលោកអ្នកវិញ ។

## ការកាត់ក្តីរបស់ក្រុមប្រឹក្សាសើរើពិនិត្យសុខភាពផ្លូវចិត្ត

ការកាត់ក្តីនឹងប្រព្រឹត្តឡើងនៅក្នុងមន្ទីរពេទ្យ ឬនៅមណ្ឌលថែរក្សាសុខភាពផ្លូវចិត្តសហគមន៍។ ជាធម្មតាការកាត់ក្តីរបស់លោកអ្នកត្រូវបានចូលរួមដោយសមាជិកបីរូបរបស់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពៈ មេធាវី ពេទ្យវិកលចរិត និងសមាជិកសហគមន៍។ បើសិនជាការកាត់ក្តីនេះជាការពិនិត្យសើរើប្រចាំឆ្នាំនៃការព្យាបាលដោយមិនស្ម័គ្រចិត្តរបស់លោកអ្នក ឬការពិនិត្យសើរើនៃការពន្យាពេល CTO ពេលនោះការកាត់ក្តីអាចចូលរួមដោយសមាជិកក្រុមប្រឹក្សាតែម្នាក់ៈ មេធាវី ឬពេទ្យព្យាបាលជំងឺវិកលចរិត ឬសមាជិកសហគមន៍របស់ក្រុមប្រឹក្សា។

ការកាត់ក្តីនេះនឹងប្រព្រឹត្តឡើងក្នុងលក្ខណៈឯកជន និងមិនជាផ្លូវការ លើកលែងតែគណកម្មាធិការសំរេចចិត្តថា វាជាផលប្រយោជន៍ដ៏ល្អបំផុតរបស់លោកអ្នក ឬរបស់សាធារណៈ នោះការកាត់ក្តីនឹងប្រព្រឹត្តឡើងជាចំហ។ វេជ្ជបណ្ឌិត ឬសមាជិកក្រុមព្យាបាលរូបលោកអ្នកនឹងផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាពិនិត្យសើរើ។ ខាងភាគីលោកអ្នក គឺលោកអ្នក និងតំណាងរបស់លោកអ្នកនឹងអាចសួរសំនួរទាំងឡាយ ព្រមទាំងអាចពន្យល់ពីករណីរបស់លោកអ្នក ឧទាហរណ៍មូលហេតុដែលលោកអ្នកជឿជាក់ថាលោកអ្នកមិនគួរឋិតនៅក្នុងបទបញ្ជាព្យាបាលដោយមិនស្ម័គ្រចិត្ត។

ជាបឋមក្រុមប្រឹក្សានឹងធ្វើការពិចារណាលក្ខខ័ណ្ឌសុខភាពបច្ចុប្បន្នរបស់លោកអ្នក ហើយក៏នឹងពិចារណាស្ថានភាពនៃសុខភាពទូទៅនិងសុខភាពផ្លូវចិត្តរបស់លោកអ្នក ព្រមទាំងស្ថានភាពសង្គមរបស់លោកអ្នក មុនធ្វើការសំរេចចិត្តរបស់ខ្លួន។

បើសិនជាលោកអ្នកជាអ្នកជំងឺស្នាក់ក្នុងមន្ទីរពេទ្យ ហើយកំពុងតែឈឺធ្ងន់ធ្ងរនៅពេលកាត់ក្តី នោះក្រុមប្រឹក្សានឹងទៅពិនិត្យលោកអ្នកដល់មន្ទីរពេទ្យ។

## សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត ស្តីពីបណ្តឹងតវ៉ា ឬការពិនិត្យសើរើនៃស្ថានភាពព្យាបាលដោយមិនស្ម័គ្រចិត្ត

ក្រុមប្រឹក្សាត្រូវតែសំរេចចិត្តថាតើលោកអ្នកនៅតែមានរាល់ចំណុចនៃលក្ខណៈអ្នកជំងឺដោយមិនស្ម័គ្រចិត្តទៀតឬទេ។

### ការបញ្ចប់ពីស្ថានភាពអ្នកជំងឺដោយមិនស្ម័គ្រចិត្ត

ប្រសិនបើលោកអ្នកពុំមានចំនុចណាមួយដែលជាលក្ខណៈអ្នកជំងឺព្យាបាលដោយមិនស្ម័គ្រចិត្ត ពេលនោះលោកអ្នកនឹងលែងឋិតនៅក្នុងបទបញ្ជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត ហើយក៏លែងជាអ្នកជំងឺព្យាបាលដោយមិនស្ម័គ្រចិត្តទៀតដែរ។ បើសិនជាលោកអ្នកឋិតនៅក្នុងបទបញ្ជាព្យាបាលតាមសហគមន៍ ពេលនោះលោកអ្នកក៏នឹងពុំឋិតនៅក្នុងបទបញ្ជានេះទៀតដែរ។ លោកអ្នកអាចពិភាក្សាអំពីការព្យាបាលបន្តតាមមូលដ្ឋានស្ម័គ្រចិត្តជាមួយប្រធានគ្រប់គ្រងករណី ឬពេទ្យព្យាបាលវិកលចរិតរបស់លោកអ្នក។ បើសិនជាលោកអ្នកជាអ្នកជំងឺស្នាក់ក្នុងមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ពេលនោះលោកអ្នកនឹងមានសេរីភាពចាកចេញពីមន្ទីរពេទ្យនេះ។ ទោះជាដូច្នេះក្តី បើរូបលោកអ្នក និងពេទ្យវិកលចរិតរបស់លោកអ្នកគិតថា លោកអ្នកនឹងមានផលប្រយោជន៍ពីការព្យាបាលបន្តនៅក្នុងមណ្ឌលសុខភាពផ្លូវចិត្ត លោកអ្នកអាចសុំការ ស្នាក់នៅជាបន្តតាមមូលដ្ឋានស្ម័គ្រចិត្ត។

### ការបន្តនៃស្ថានភាពអ្នកជំងឺដោយមិនស្ម័គ្រចិត្ត

ប្រសិនបើជាក្រុមប្រឹក្សាពិនិត្យសើរើសំរេចចិត្តថា លោកអ្នកនៅតែមានរាល់ចំនុចនៃលក្ខណៈអ្នកជំងឺដោយមិនស្ម័គ្រចិត្ត នោះលោកអ្នកនឹងនៅតែបន្តទទួលការព្យាបាលក្នុងនាមជាអ្នកជំងឺដោយមិនស្ម័គ្រចិត្ត។ បើសិនលោកអ្នកជាអ្នកជំងឺស្នាក់នៅក្នុងមន្ទីរពេទ្យ ហើយក្រុមប្រឹក្សាពិចារណាថា លោកអ្នកអាចទទួលការព្យាបាលដែលលោកអ្នកត្រូវការតាមរយៈ CTO ក្រុមប្រឹក្សាអាចបញ្ជាពេទ្យវិកលចរិតរបស់លោកអ្នកឱ្យដាក់លោកអ្នកនៅក្នុងបទបញ្ជាព្យាបាលតាមសហគមន៍។ បើសិនជាលោកអ្នកឋិតនៅក្នុងបទបញ្ជាព្យាបាលតាមសហគមន៍ ក្រុមប្រឹក្សាអាចផ្លាស់ប្តូរលក្ខខ័ណ្ឌនៃបទបញ្ជានេះ។ បើសិនជាក្រុមប្រឹក្សាធ្វើនិរាករណ៍ CTO របស់លោកអ្នក លោកអ្នកត្រូវវិលត្រឡប់ទៅកាន់មន្ទីរពេទ្យសុខភាពផ្លូវចិត្តវិញ។

ក្រុមប្រឹក្សាក៏នឹងពិនិត្យសើរើផែនការព្យាបាលរបស់លោកអ្នកផងដែរ ដើម្បីសំរេចពីដំណើរការត្រឹមត្រូវដែលយកមកប្រើប្រាស់សំរាប់ការធ្វើផែនការនេះ។ ឧទាហរណ៍ ដូចជាថាតើគេគិតគូរពីបំណងរបស់លោកអ្នកឬទេ ឬពេទ្យវិកលចរិតពិចារណា វិធីព្យាបាលផ្សេងទៀតឬទេ។ ក្រុមប្រឹក្សាត្រូវតែពេញចិត្តថា មណ្ឌលថែទាំសុខភាពផ្លូវចិត្តអាចអនុវត្តផែនការនេះបាន។

នៅចុងបញ្ចប់នៃការកាត់ក្តី ក្រុមប្រឹក្សានឹងជំរាបលោកអ្នក ពីសេចក្តីសំរេចចិត្តរបស់ខ្លួន និងមូលហេតុនៃការធ្វើសេចក្តីសំរេចចិត្តនេះ។ លោកអ្នកនឹងទទួលបានច្បាប់ចំឡងនៃសេចក្តីសំរេចចិត្តនេះ។ បើសិនជាលោកអ្នកចង់បានមូលហេតុនៃការធ្វើសេចក្តីសំរេចចិត្តនេះជាលាយលក្ខអក្សរ លោកអ្នកត្រូវតែ ស្នើជាលាយលក្ខអក្សរទៅកាន់ក្រុមប្រឹក្សាក្នុងរយៈពេល២៨ថ្ងៃ ហើយក្រុមប្រឹក្សាត្រូវតែផ្តល់ជូនលោកអ្នកនូវសេចក្តីប្រកាសមួយអំពីមូលហេតុទាំងនោះ ក្នុងរយៈពេល១៤ថ្ងៃនៃការស្នើសុំរបស់លោកអ្នក។ លោកអ្នកអាចប្តឹងតវ៉ាម្តងទៀតនៅពេលណាក៏បានទៅកាន់ក្រុមប្រឹក្សាពិនិត្យសើរើនេះ។

## ការពិនិត្យសើរើនៃសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត

ប្រសិនបើលោកអ្នកមិនយល់ស្របនឹងសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាទេ លោកអ្នកអាចដាក់ពាក្យប្តឹងទៅកាន់តុលាការស៊ីវិល និងរដ្ឋបាលរបស់រដ្ឋវិចតូរីយ៉ា VCAT សំរាប់ការសើរើពិនិត្យនូវសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត។ VCAT គឺជាតុលាការឯករាជ្យ ដែលមានអំណាចបញ្ជាក់ ឬកែប្រែសេចក្តីសំរេចចិត្តរបសក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្តបាន។

ពាក្យបណ្តឹងត្រូវសរសេរជាលាយលក្ខអក្សរក្នុងរយៈពេល២៨ថ្ងៃ បន្ទាប់ពីការចេញសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាពិនិត្យសើរើសុខភាពផ្លូវចិត្ត ឬបន្ទាប់ពីការចេញសេចក្តីប្រកាសអំពីមូលហេតុនៃសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សា បើសិនជា លោកអ្នកបានស្នើសេចក្តីប្រកាសអំពីមូលហេតុនៃសេចក្តីសំរេច ចិត្តពីក្រុមប្រឹក្សាក្នុងរយៈពេល២៨ថ្ងៃ ហើយពាក្យបណ្តឹងត្រូវដាក់ទៅកាន់ៈ

Victorian Civil and Administrative Tribunal
General List
55 King Street, Melbourne Victoria 3000

ទូរស័ព្ទលេខៈ 9628 9755
ទូរសារលេខៈ 9628 9788

អង្គការដែលអាចជួយលោកអ្នកក្នុងការដាក់ពាក្យបណ្តឹងមានរាយឈ្មោះនៅខាងក្រោយនៃកូនសៀវភៅនេះ។

# បណ្តឹង

លោកអ្នកគួរទទួលការប្រព្រឹត្តអំពើមកលើដែលប្រកបដោយកិត្តិយសនិងការគោរព និងត្រូវបានការពារទល់នឹងការប្រព្រឹត្តអំពើមិនគប្បីមកលើ នៅពេលលោកអ្នកទទួលការព្យាបាលនិងការថែទាំសំរាប់ស្ថានភាពជំងឺរបស់លោកអ្នក។

បើលោកអ្នកមិនពេញចិត្តអំពីផ្នែកណាមួយនៃការព្យាបាលឬការថែទាំលោកអ្នកទេ លោកអ្នកអាចធ្វើបណ្តឹងបាន។ កន្លែងល្អសំរាប់ចាប់ផ្តើមគឺជាមួយប្រធានករណីលោកអ្នក គិលានុបដ្ឋាកសំខាន់ ឬសមាជិកម្នាក់ទៀតនៃក្រុមព្យាបាល មន្ត្រីទំនាក់ទំនងបណ្តឹង ឬអ្នកពិគ្រោះយោបល់អ្នកប្រើប្រាស់នៅក្នុងមន្ទីរពេទ្យវេជ្ជបណ្ឌិតឬគ្រូពេទ្យសរសៃប្រសាទលោកអ្នក ប៉ុន្តែយកផ្នែកសរសៃប្រសាទនៅឯសេវាសុខភាពផ្លូវចិត្ត។

លោកអ្នកក៏អាចធ្វើបណ្តឹងដោយផ្ទាល់ទៅកាន់ស្នងការសេវាសុខភាព *(Health Services Commissioner)* ផងដែរ តាមទូរស័ព្ទលេខ 8601 5200 ឬប្រធានគ្រូពេទ្យសរសៃប្រសាទ តាមលេខ 1300 767 299 ។

បើលោកអ្នកត្រូវការជំនួយក្នុងការធ្វើបណ្តឹងរបស់លោកអ្នក លោកអ្នកអាចសុំជំនួយពីជនណាមួយដែលលោកអ្នកទុកចិត្ត។ ជននេះប្រហែលជាសមាជិកនៃក្រុមព្យាបាល មិត្តភក្តិ សមាជិកគ្រួសារ មេធាវី ឬអ្នកសាកសួរសុខទុក្ខមកពីសហគមន៍។

# ការទាក់ទងសំខាន់ៗ

អង្គការទាំងឡាយដែលលោកអ្នកអាចទាក់ទងសុំជំនួយ និងទទួលព័ត៌មានបន្ថែមមានរាយឈ្មោះនៅខាងក្រោមនេះ។

- **ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញអំពីសុខភាពផ្លូវចិត្ត *(Mental Health Review Board)***
  គឺជាសាលាក្តីមិនប្រកាន់ភាគី ខាងណាមួយដែលស្តាប់បណ្តឹងតវ៉ាពីអ្នកជំងឺមិនស្ម័គ្រចិត្ត អ្នកជំងឺក្រោមបញ្ជាព្យាបាលមិនស្ម័គ្រចិត្តដែលមានកំរិតកំណត់ និងអ្នកជំងឺជាប់ឃុំឃាំងក្នុងសេវាសុខភាពផ្លូវចិត្តដែលចង់ចេញពីស្ថានភាពព្យាបាលដោយមិនស្ម័គ្រចិត្តរបស់ខ្លួន។ ក្រុមប្រឹក្សានេះក៏ពិនិត្យមើលឡើងវិញនូវអ្នកជំងឺទាំងនេះដោយស្វ័យប្រវត្តិផងដែរ។

  Level 30, Marland House,
  570 Bourke Street, Melbourne 3000
  ទូរស័ព្ទ៖ 8601 5270
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 242 703
  ទូរសារ៖ 8601 5299
  អ៊ីមែល៖ mhrb@mhrb.vic.gov.au
  វិបសៃ៖ www.mhrb.vic.gov.au

- **អ្នកសាកសួរសុខទុក្ខមកពីសហគមន៍ *(Community visitors)*** គឺជាអ្នកដែលអញ្ជើញទៅកាន់សេវាសុខភាពផ្លូវចិត្តយ៉ាងតិចក៏ម្តងដែរក្នុងមួយខែ ដើម្បីសាកសួរអំពីភាពគ្រប់គ្រាន់នៃសេវានិងគ្រឿងប្រដាប់ប្រដារ សំរាប់ការព្យាបាលនិងការថែទាំអ្នកជំងឺ ស៊ើបអង្កេតបណ្តឹង និងរាយការណ៍អំពីការសាកសួរនិងការស៊ើបអង្កេតរបស់ខ្លួន។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **មណ្ឌលផ្នែកច្បាប់សុខភាពផ្លូវចិត្ត *(Mental Health Legal Centre)*** គឺជាសេវាឯករាជ្យផ្នែកច្បាប់ដែលមានឯកទេសខាងបញ្ហាច្បាប់សុខភាពផ្លូវចិត្ត។ មណ្ឌលនេះអាចរៀបចំធ្វើជាតំណាងជូនលោកអ្នកនៅឯការស្តាប់ក្តីរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញលើសុខភាពផ្លូវចិត្ត ឬផ្តល់ឱវាទអំពីបញ្ហាផ្លូវច្បាប់ផ្សេងទៀត។

  9th Floor, 10–16 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9629 4422
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 555 887

- **ជំនួយផ្នែកច្បាប់រដ្ឋវិចតូរីយ៉ា *(Victoria Legal Aid)*** ផ្តល់ឱវាទផ្នែកច្បាប់ដោយឥតគិតថ្លៃអំពីបញ្ហាផ្សេងៗគ្នាជាច្រើន។ ស្ថាប័ននេះក៏ផ្តល់ជំនួយផ្នែកច្បាប់ផងដែរ បើលោកអ្នកគ្មានប្រាក់ជួលមេធាវីឯកជនបាន ហើយក៏អាចជួយឡើងបកស្រាយផ្នែកច្បាប់នៅឯការប្រជុំរបស់ក្រុមប្រឹក្សាពិនិត្យមើលឡើងវិញផ្នែកសុខភាពផ្លូវចិត្តផងដែរ។

  350 Queen Street, Melbourne 3000
  ទូរស័ព្ទ៖ 9269 0234
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 677 402

- **អ្នកគាំទ្រសាធារណៈ *(Public Advocate)*** ជួយផ្តល់ឱវាទនិងគាំទ្រអ្នកដែលមានបណ្តឹងធ្ងន់ធ្ងរអំពីសេវានិងការព្យាបាលសុខភាពផ្លូវចិត្តនិងពិការភាព។

  5th Floor, 436 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9603 9500
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 309 337

- **គណៈកម្មការឱកាសស្មើគ្នានិងសិទ្ធិមនុស្សរដ្ឋវិកតូរីយ៉ា *(Victorian Equal Opportunity and Human Rights Commission)*** ជួយបណ្តាជនក្នុងការដោះស្រាយបណ្តឹងអំពីការប្រកាន់រើសអើង មានមុខងាររជាក់លាក់ដែលទាក់ទងនឹងលក្ខន្តិកៈនៃសិទ្ធិមនុស្សនិងការទទួលខុសត្រូវ ហើយអាចផ្តល់ឱវាទអំពីលក្ខន្តិកៈនេះ។

  សេវាទាំងពួងមានរួមទាំងទូរស័ព្ទសាកសួរ និងសេវាដោះស្រាយបណ្តឹងដោយលាក់ការ ឥតគិតថ្លៃ និងមិនលំអៀង។

  Level 3, 380 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9281 7100
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 13 41 42
  វិបសៃ៖ www.humanrightscommission.vic.gov.au

- **ប្រធានគ្រូពេទ្យសរសៃប្រសាទ *(Chief Psychiatrist)*** គឺជាមន្ត្រីជាន់ខ្ពស់នៃក្រសួងសេវាពលរដ្ឋ ដែលតែងតាំងនៅក្រោមច្បាប់សុខភាពផ្លូវចិត្ត ដោយមានការទទួលខុសត្រូវពិសេសទាក់ទងនឹងអ្នកទទួលសេវាសុខភាពផ្លូវចិត្ត។ ការទទួលខុសត្រូវទាំងនេះមានរួមទាំងអំណាចដើម្បីស៊ើបអង្កេតបណ្តឹងនិងបញ្ហាឯទៀតនិងដើម្បីចាត់ឲ្យមានវិធានការចាំបាច់។

  50 Lonsdale Street, Melbourne 3000
  ទូរស័ព្ទ៖ 9096 7571
  ទូរស័ព្ទឥតគិតថ្លៃ៖ 1300 767 299

- **ស្នងការសេវាសុខភាព *(Health Services Commissioner)*** គឺជាស្នងការមិនប្រកាន់ខាងណាដែលស៊ើបអង្កេតនិងជួយដោះស្រាយបណ្តឹងដោយអ្នកប្រើប្រាស់ការថែទាំសុខភាព អំពីសេវាសុខភាពដោយមានរួមទាំងសេវាសុខភាពផ្លូវចិត្ត។ ស្នងការនេះអាចជួយអ្នកជំងឺដើម្បីទទួលព័ត៌មានអំពីសុខភាពរបស់ខ្លួន។

  30th Floor, 570 Bourke Street, Melbourne 3000
  ទូរស័ព្ទ៖ 8601 5200
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 136 066

- **មន្ត្រីស៊ើបអង្កេតបណ្តឹងអំពីមន្ត្រីរដ្ឋការ *(Ombudsman)***
  ស៊ើបអង្កេតបណ្តឹងអំពីក្រសួងរបស់រដ្ឋាភិបាល។
  3rd Floor, 459 Collins Street, Melbourne 3000
  ទូរស័ព្ទ៖ 9613 6222
  ទូរស័ព្ទឥតគិតថ្លៃ៖ 1800 806 314

លោកអ្នកក៏អាចសាកសួរប្រធានករណីរបស់លោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាលផងដែរ អំពីអង្គការឯទៀតក្នុងតំបន់ និងក្រុមជំនួយទាំងឡាយ ដែលអាចជួយលោកអ្នកបាន។

## កូនសៀវភៅដែលបោះផ្សាយជាស៊េរី "អំពីសិទ្ធិរបស់លោកអ្នក"៖

- អ្នកជំងឺមិនស្ម័គ្រចិត្ត *(Involuntary patients)*
- បញ្ជាឲ្យទទួលការព្យាបាលដោយមិនស្ម័គ្រចិត្តក្រោមការត្រួតពិនិត្យ *(Restricted involuntary treatment orders)*
- អ្នកជំងឺជាប់ឃុំឃាំង *(Security patients)*
- អ្នកជំងឺនីតិក្រម *(Forensic patients)*
- ការព្យាបាលដោយវិធីឆក់ខ្សែភ្លើង *(Electroconvulsive therapy)*
- ការព្យាបាលចំបងដែលមិនពាក់ព័ន្ធនឹងជំងឺសរសៃប្រសាទ *(Major non-psychiatric treatment)*
- បញ្ជាមើលខុសត្រូវមិននៅក្រោមការឃុំឃាំង *(Non-custodial supervision orders)*

## កូនសៀវភៅផ្សេងទៀតនៅក្នុងស៊េរី "អំពីសិទ្ធិរបស់លោកអ្នក"៖

- អ្នកជំងឺនីតិក្រម (បញ្ជាឃុំខ្លួននិងមើលខុសត្រូវបណ្តោះអាសន្ន) *(Forensic (remand and interim disposition order) patients)*
- អ្នកជំងឺមិនស្ម័គ្រចិត្តបន្តការព្យាបាលតទៅទៀត (មាត្រាទី 12A – 12D) *(Continuing treatment (section 12A-12D) involuntary patients)*
- បញ្ជាពិនិត្យវាយតម្លៃ និងបញ្ជារោគវិនិច្ឆ័យ ពិនិត្យវាយតម្លៃនិងព្យាបាល *(Assessment orders and diagnosis, assessment and treatment orders)*
- ការវះកាត់ព្យាបាលរោគផ្លូវចិត្ត *(Psychosurgery)*

កូនសៀវភៅទាំងនេះនិងកូនសៀវភៅឯទៀត មាននៅតាមវ៉ិបសៃ www.health.vic.gov.au/mentalhealth ដោយមានអក្សរធំៗ។
មានកូនសៀវភៅមួយចំនួនជាភាសាផ្សេងទៀតផងដែរ។

## សេវាទូរស័ព្ទផ្តល់ព័ត៌មាន

លោកអ្នកអាចស្តាប់ព័ត៌មានថតទុកអំពីអ្នកជំងឺមិនស្ម័គ្រចិត្ត ជាភាសាមួយចំនួន តាមរយៈការទូរស័ព្ទទៅកាន់សេវាទូរស័ព្ទផ្តល់ព័ត៌មាន។

សេវាទូរស័ព្ទនេះធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ។

| | |
|---|---|
| អង់គ្លេស | 9679 9838 |
| អារ៉ាប់ | 9679 9825 |
| ខ្មែរ | 9679 9826 |
| ចិនកន្តាំង | 9679 9827 |
| ក្រូអាត | 9679 9828 |
| ក្រិក | 9679 9829 |
| អ៊ីតាលី | 9679 9830 |
| ម៉ាសេដូនី | 9679 9831 |
| ចិនកុកងឺ | 9679 9837 |
| ស៊ែប៊ី | 9679 9834 |
| សូម៉ាលី | 9679 9832 |
| អេស្ប៉ាញ | 9679 9833 |
| ទួរគី | 9679 9835 |
| វៀតណាម | 9679 9836 |

បោះពុម្ពផ្សាយដោយផ្នែកសុខភាពផ្លូវចិត្តនិងឱសថ (Mental Health and Drugs Division)
ក្រសួងសេវាពលរដ្ឋរបស់រដ្ឋាភិបាលរដ្ឋវិកតូរីយ៉ា ក្រុងមែលប៊ន រដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី។
© សិទ្ធិចំលងនៃរដ្ឋវិចតូរីយ៉ា ក្រសួងសេវាពលរដ្ឋ ឆ្នាំ 2008 ។ .
អាចផលិតឡើងវិញនូវឯកសារនេះ ជាផ្នែកឬទាំងស្រុង បើមានការទទួលស្គាល់សិទ្ធិចំលង។
ខែកញ្ញា 2008 (080519)
អនុញ្ញាតដោយរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ក្រុងមែលប៊ន។

**តើលោកអ្នកត្រូវការកូនសៀវភៅនេះតាមទំរង់មួយទៀតឬទេ?**

បើលោកអ្នកត្រូវការកូនសៀវភៅនេះជាទំរង់មួយទៀត លោកអ្នកគួរពិភាក្សាជាមួយ ប្រធានករណីលោកអ្នក ឬសមាជិកណាមួយនៃក្រុមព្យាបាល។

State Government Victoria
Department of Human Services